# សុន្ទរកថារបស់លោក យូណាមីណិ ម៉ូរីយ៉ាស៊ូ
# លេខាទី២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធអគារជម្ងឺឆ្លង នៅមន្ទីរពេទ្យខេត្តកំពង់ធំ

ថ្ងៃទី០៨ ខែ មករា ឆ្នាំ ២០១៦

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!
- សូមគោរព ឯកឧត្តម តែ គុយស៊ាង រដ្ឋលេខាធិការក្រសួងសុខាភិបាល
- ឯកឧត្តម អ៊ុតសំអន អភិបាលខេត្តកំពង់ធំ
- លោកវេជ្ជបណ្ឌិត ស្រី ស៊ីន ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ធំ
- សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានមកចូលរួមពិធីសម្ពោធអគារជម្ងឺឆ្លង នៅមន្ទីរពេទ្យខេត្ត កំពង់ធំនេះ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម តែ គុយស៊ាង**។ ជាបឋមខ្ញុំ សូមសំដែងនូវការដឹងគុណ ដ៏ជ្រាលជ្រៅ ចំពោះឯកឧត្តមរដ្ឋលេខាធិការ ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ។

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការកសាងឡើងវិញ និងការអភិវឌ្ឍប្រទេសរបស់ខ្លួន ហើយក៏បានធ្វើអោយសម្រេចនូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់បំផុតរបស់ខ្លួន ស្មើនឹងបណ្តាប្រទេសកំពុងរីកចំរើនក្នុងតំបន់អាស៊ាន។ នៅក្នុងវិស័យសុខាភិបាល ទាំងបរិមាណនិងគុណភាពមានភាពប្រសើរឡើងយ៉ាងខ្លាំងផងដែរ តាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និងសហគមន៍អន្តរជាតិ។

រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ ជាពិសេសនោះ ក៏មានការយកចិត្តទុកដាក់ក្នុងការកែលម្អផ្នែកអគារវេជ្ជសាស្ត្រនានាជាដើម។

គម្រោងនេះ ធ្វើការសាងសង់នូវអគារជម្ងឺឆ្លង នៅក្នុងមន្ទីរពេទ្យខេត្តកំពង់ធំ។ ដោយសារតែចំនួនអ្នកជម្ងឺ នៅក្នុងមន្ទីរពេទ្យខេត្តកំពង់ធំ មានការកើនឡើងយ៉ាងឆាប់រហ័សនៅប៉ុន្មានឆ្នាំថ្មីៗនេះ បានធ្វើអោយមានការកើនឡើងខ្ពស់នៃអត្រាជម្ងឺឆ្លងគួរអោយកត់សំគាល់ ដោយសារតែអ្នកជម្ងឺស្នាក់នៅពាសពេញមន្ទីរពេទ្យ។ អគារជម្ងឺឆ្លងថ្មីនេះ ត្រូវបានគាំទ្រក្រោមជំនួយឧបត្ថម្ភឥតសំណងទ្រង់ទ្រាយតូចរបស់ជប៉ុន នឹងអនុញ្ញាតអោយអ្នកជម្ងឺកាន់តែច្រើនឡើង ទទួលបានការព្យាបាលប្រកបដោយសុវត្ថិភាព និងក្នុងបរិស្ថានប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដោយហេតុនេះ យើងសង្ឃឹមថាគម្រោងនេះ នឹងរួមចំណែកជួយកែលម្អធ្វើអោយប្រសើរឡើងស្ថានភាពសុខភាពនៅក្នុងតំបន់។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អគារជម្ងឺឆ្លងថ្មីនេះ នឹងពង្រីកការផ្តល់សេវាសុខភាពបន្ថែមទៀតក្នុងខេត្តកំពង់ធំ ហើយជាលទ្ធផលប្រជាពលរដ្ឋជាច្រើន នឹងទទួលបានអត្ថប្រយោជន៍ពីសេវាសុខភាពដែលផ្តល់ដោយមន្ទីរពេទ្យល្អប្រសើរជាងមុន ។ ខ្ញុំសង្ឃឹមថា អគារជម្ងឺឆ្លងនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ និងប្រើប្រាស់បានយូរអង្វែង ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!